**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៥៣៨ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ភ្នំរាំង ស្ថិតនៅឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ២១៩ ប្រក.កសក. ចុះថ្ងៃទី២១ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្តនិងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## សម្រេច

**ប្រការ១ .–**

ត្រូវបានបង្កើតតំបន់ព្រៃសហគមន៍ភ្នំរាំង សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ មានទីតាំងស្ថិតនៅក្នុងឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។

**ប្រការ២ .–**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍន៍ព្រៃសហគមន៍ឲ្យមានចីរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្ដានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

**ប្រការ៣ .–**

តំបន់ព្រៃសហគមន៍ភ្នំរាំង មានផ្ទៃក្រឡាសរុបទំហំ២៩៤(ពីររយកៅសិបបួន)ហិកតា ដូចមានផែនទីភ្ជាប់មកជាឧបសម្ព័ន្ធនៃប្រកាសនេះ និងមាននិយាមកាចំណុចគោល(Datum: WGS1984)ដូចខាងក្រោម៖

| ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) | ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) | ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) |
|---|---|---|---|---|---|---|---|---|
| 1 | 554330 | 1400610 | 12 | 555964 | 1401110 | 23 | 556562 | 1400450 |
| 2 | 554493 | 1400610 | 13 | 556010 | 1401170 | 24 | 556108 | 1400330 |
| 3 | 554968 | 1400830 | 14 | 556264 | 1401370 | 25 | 555896 | 1400330 |
| 4 | 554958 | 1400890 | 15 | 556546 | 1401450 | 26 | 555595 | 1400160 |
| 5 | 555243 | 1400990 | 16 | 556608 | 1401330 | 27 | 555380 | 1399990 |
| 6 | 555391 | 1401000 | 17 | 556903 | 1401330 | 28 | 555098 | 1399890 |
| 7 | 555561 | 1401120 | 18 | 557485 | 1401020 | 29 | 554897 | 1399790 |
| 8 | 555567 | 1401180 | 19 | 557552 | 1400880 | 30 | 554773 | 1399640 |
| 9 | 555802 | 1401190 | 20 | 557332 | 1400840 | 31 | 554160 | 1399470 |
| 10 | 555830 | 1401220 | 21 | 556984 | 1400560 | 32 | 554059 | 1399720 |
| 11 | 555889 | 1401110 | 22 | 556752 | 1400610 | 33 | 554260 | 1400410 |

**ប្រការ៤ .–**

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្ដីពីព្រៃឈើ អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

**ប្រការ៥ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .—**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងរ៉ែនិងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ធំ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៥៣៨ ប្រក.កសក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៧

ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ភ្នំរាំង ស្ថិតនៅឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ




ចំណុចនិយាមកាព្រៃសហគមន៍

| ចំណុចគោល | អាប់ ស៊ីស | អរដោនេ | ចំណុចគោល | អាប់ ស៊ីស | អរដោនេ | ចំណុចគោល | អាប់ ស៊ីស | អរដោនេ |
|---|---|---|---|---|---|---|---|---|
| 1 | 554330 | 1400610 | 12 | 555964 | 1401110 | 23 | 556562 | 1400450 |
| 2 | 554493 | 1400610 | 13 | 556010 | 1401170 | 24 | 556108 | 1400330 |
| 3 | 554968 | 1400830 | 14 | 556264 | 1401370 | 25 | 555896 | 1400330 |
| 4 | 554958 | 1400890 | 15 | 556546 | 1401450 | 26 | 555595 | 1400160 |
| 5 | 555243 | 1400990 | 16 | 556608 | 1401330 | 27 | 555380 | 1399990 |
| 6 | 555391 | 1401000 | 17 | 556903 | 1401330 | 28 | 555098 | 1399890 |
| 7 | 555561 | 1401120 | 18 | 557485 | 1401020 | 29 | 554897 | 1399790 |
| 8 | 555567 | 1401180 | 19 | 557552 | 1400880 | 30 | 554773 | 1399640 |
| 9 | 555802 | 1401190 | 20 | 557332 | 1400840 | 31 | 554160 | 1399470 |
| 10 | 555830 | 1401220 | 21 | 556984 | 1400560 | 32 | 554059 | 1399720 |
| 11 | 555889 | 1401110 | 22 | 556752 | 1400610 | 33 | 554260 | 1400410 |